## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

លេខ.........✓...........ក.អ.ក

ក្លិបអ្នកកាសែតកម្ពុជា
ប្រធាន
លោក ពុយ គា
អគ្គលេខាធិការ
លោកស្រី ចុង សុវណ្ណរង្សី
គណៈកម្មាធិការនាយក
លោក ខៀវ កូឡា
លោក ជេត សន
លោក ទាវ សារៈមុនី
លោក នៅ សុភ័ស្ស
កញ្ញា យ៉ាន់ លីណា
លោក លាង ដឺលុច
លោក សៅ ភិរុណ
សមាជិកស្ថាបនិក
លោក ប៉ែន សមិទ្ធិ
លោក ឆាយ សុផល
លោក ខៀវ កូឡា
លោក ជេត សន
លោក ខាន់ សុឃន
លោក រាជ សម្បត្តិ
លោក សាំង សុគន្ធរិទ្ធ
លោក ជិន ចាន់មុនី
លោក ប្រាជ្ញ ស៊ីម
លោក យួន វិចិត្រ
លោក រស់ ចាន់សន
លោក កែវ សុធា
លោក ឯក សំអាត
លោក ផាន់ សីហា
លោក ឈា វិរី
អ្នកស្រី សុជាត នារីគ្មន៍
លោក យូ បូ

# សេចក្តីប្រកាសព័ត៌មាន

ក្លិបអ្នកកាសែតកម្ពុជា **(ក.អ.ក)** កត់សម្គាល់ឃើញថា មួយរយៈចុងក្រោយនេះនៅតែមានអ្នកសារព័ត៌មានជាបន្តបន្ទាប់បានប្រឈមនឹងការឃាត់ខ្លួនពីសមត្ថកិច្ច ពាក់ព័ន្ធនឹងការបំពានលើក្រមសីលធម៌និងវិជ្ជាជីវៈដែលនាំឱ្យប៉ះពាល់ដល់ការលើកកម្ពស់វិស័យសារព័ត៌មាននៅកម្ពុជា។ ជាក់ស្តែងថ្មីៗនេះ អ្នកសារព័ត៌មាន៤រូបត្រូវបានសមត្ថកិច្ចខេត្តមណ្ឌលគិរីឃាត់ខ្លួន ដែល **ក.អ.ក** យល់ថា អាចមកពីកង្វះខាតក្នុងការអនុវត្តក្រមសីលធម៌ និងវិជ្ជាជីវៈផ្នែកសារព័ត៌មាន ។

**ក.អ.ក** មិនបានចាត់ទុកករណីនេះជាបញ្ហាថ្មីសម្រាប់ស្ថានភាពសារព័ត៌មាននៅកម្ពុជានោះទេ ប៉ុន្តែអ្វីដែល **ក.អ.ក** ចង់រំលេចឱ្យឃើញនោះគឺ ទាំងស្ថាប័នជំនាញ ទាំងសមាគមសារព័ត៌មាន ជាពិសេសក្លិបអ្នកកាសែតកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ក្នុងការបើកវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយ អប់រំដល់អ្នកសារព័ត៌មានអំពីក្រមសីលធម៌និងវិជ្ជាជីវៈ រួមទាំងការលើកទឹកចិត្តអ្នកសារព័ត៌មានក្នុងការអនុវត្តនូវក្រមសីលធម៌និងវិជ្ជាជីវៈ ហើយជាទូទៅអ្នកសារព័ត៌មានជាច្រើនបានយល់ដឹង និងបានចូលរួមអនុវត្តដោយស្មារតីទទួលខុសត្រូវ។ ប៉ុន្តែអ្នកសារព័ត៌មានមួយចំនួនហាក់ដូចជាមិនទាន់អនុវត្តបាន ដែលជាហេតុនាំឱ្យមានការឃាត់ខ្លួនដោយសារតែការធ្វេសប្រហែស ឬមើលរំលងនូវក្រមសីលធម៌និងវិជ្ជាជីវៈ។

**ក.អ.ក** ចាត់ទុក ក្រមសីលធម៌និងវិជ្ជាជីវៈ មិនគ្រាន់តែជួយអ្នកសារព័ត៌មានពីការចោទប្រកាន់ពីបទល្មើស ឬឃាត់ខ្លួននោះទេ តែក្រមសីលធម៌និងវិជ្ជាជីវៈនេះហើយដែលជួយត្រួសត្រាយផ្លូវអ្នកសារព័ត៌មានក្នុងការលើកកម្ពស់ជីវភាពរស់នៅប្រកបដោយភាពថ្លៃថ្នូរ និងរួមចំណែកក្នុងការអភិវឌ្ឍវិស័យសារព័ត៌មាននៅកម្ពុជា ។

**ក.អ.ក** ជាថ្មីម្តងទៀត អំពាវនាវដល់អ្នកសារព័ត៌មានទាំងអស់ត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌និងវិជ្ជាជីវៈ ដែលជាអាវក្រោះការពារខ្លួនឯងផង និងលើកតម្កើងសេរីភាពសារព័ត៌មានផងដែរ។

**ក.អ.ក** សង្ឃឹមយ៉ាងមុតមាំថា អ្នកសារព័ត៌មានទាំងអស់នឹងបន្តដំណើរជាមួយ **ក.អ.ក** ក៏ដូចជាសមាគមសារព័ត៌មានផ្សេងទៀត ដើម្បីលើកកម្ពស់ការអនុវត្តនូវក្រមសីលធម៌និងវិជ្ជាជីវៈសារព័ត៌មាន សំដៅធ្វើយ៉ាងណាឱ្យស្ថាប័នសារព័ត៌មាន និងអ្នកសារព័ត៌មានរក្សាបាននូវកិត្តិយស សេចក្តីថ្លៃថ្នូរ ចៀសវាងភាពអសកម្មដែលនាំឱ្យប៉ះពាល់ដល់ការអភិវឌ្ឍវិស័យសារព័ត៌មាននៅកម្ពុជា ។

**ក.អ.ក** សូមជម្រាបជូនថា នៅចុងឆ្នាំនេះ **ក.អ.ក** នឹងរៀបចំវេទិកានិពន្ធនាយកលើកទី២០ ដែលជាវេទិកាដ៏មានសារសំខាន់ និងធំជាងគេរបស់ **ក.អ.ក** ដោយផ្តោតលើប្រធានបទស្តីពីក្រមសីលធម៌និងវិជ្ជាជីវៈមកពិភាក្សា និងបំពេញបន្ថែមលើចំណុចខ្វះខាត ហើយនឹងចេញនូវសេចក្តីថ្លែងការណ៍រួមមួយដែលរំពឹងថា នឹងជួយរម្លឹកដល់អ្នកសារព័ត៌មានឱ្យចូលរួមកាន់តែសកម្មថែមទៀតក្នុងការអនុវត្តនិងលើកកម្ពស់ក្រមសីលធម៌និងវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាននៅកម្ពុជា៕

**ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣**

**ក្លិបអ្នកកាសែតកម្ពុជា**

Club of Cambodian Journalists

ផ្ទះលេខ ១២ ផ្លូវលេខ៥ (បុរីប៉េងហួត មុខផ្សារប៉េសេ ផ្លូវ៣៧១) សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
House N°12, Street 5 (Borey Peng Huot in front of PC Market), Sangkat Chak Engrae Lue, Khan Mean Chey, Phnom Penh, Kingdom of Cambodia.
Tel: 012 895 853 / 077 480 171 / E-mail : info@ccjcam.com / Website : www.ccjcam.com / Facebook : Club of Cambodian Journalists